https://m.freshnewsasia.com/index.php/en/localnews/8156-2015-08-10-10-33-46.html Go AUG SEP OCT
1 capture 15
15 Sep 2023 2022 2023 2024 About this capture







# តំណាងក្រុមហ៊ុន XIHU និយាយថា «ទឹកក្រហមដែលហូរចូលទឹកសមុទ្រនោះ គឺហូរចេញពីសណ្ឋាគារសុខា»

2015-08-10 05:33pm

**(ព្រះសីហនុ)៖** បន្ទាប់ពីមានការរិះគន់ថា ការដ្ឋានសំណង់សណ្ឋាគារលំដាប់ផ្កាយ៥ ឈ្មោះ XI-HU International Hotel Co., Ltd. ដែលវិនិយោគដោយជនជាតិចិន ស្ថិតក្នុងសង្កាត់លេខ៣ ក្រុងខេត្តព្រះសីហនុ នៅក្បែរឆ្នេរសណ្ឋាគារសុខា ក្រុងព្រះសីហនុ ដែលបានចាក់ដីក្រហម ហើយនៅពេលភ្លៀងធ្លាក់ម្តងៗ ហូរចូលសមុទ្រហើយធ្វើឲ្យសមុទ្រប្រែក្លាយទឹកសមុទ្រ ពីពណ៌ខៀវស្រងាត់ ទៅជាក្រហមគួរឲ្យខ្លាចនោះ។

នៅរសៀលថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥នេះ ត្រូវបានតំណាងក្រុមហ៊ុន XI-HU International Hotel Co., Ltd. បានចេញមុខអះអាងឲ្យដឹងថា «**ទឹកក្រហមដែលហូរចូល ទឹកសមុទ្រនោះ គឺហូរចេញពីសណ្ឋាគារសុខា ដែលនៅក្បែរនោះ**» មិនមែនហូរចេញពីការដ្ឋានសំណង់របស់ក្រុមហ៊ុន XI-HU International ព្រោះទីតាំងសម្រាប់សាងសង់ មិនទាន់ដំណើរការនោះទេ ហើយពាក់ព័ន្ធនឹងផ្លូវច្បាប់គឺមានឯកសារត្រឹមត្រូវ មិនមានអ្វីល្មើសច្បាប់នោះទេ។

តំណាងក្រុមហ៊ុនរូបនោះបានបញ្ជាក់ថា ក្រុមការងារសំណង់គេមានបច្ចេកទេសខ្ពស់ ក្នុងការទប់ស្កាត់មិនឲ្យទឹកហូរចូលទៅសមុទ្រដោយគ្មានការចម្រោះនោះទេ មានបច្ចេកទេសទប់ស្កាត់ដោយដាក់លូទប់ទឹក។

សំណង់សណ្ឋាគារនេះ វិនិយោគទុនដោយក្រុមហ៊ុនចិន មានតម្លៃទឹកប្រាក់ដល់ ១៧៥លានដុល្លារ កំពស់២៧ជាន់ និង ចំនួន៧០០បន្ទប់ ស្ថិតនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

ទោះបីយ៉ាងណា យើងខ្ញុំមិនអាចសុំការបំភ្លឺពីភាគីខាងសណ្ឋាគារ សុខា របស់លោកឧកញ៉ា សុខគង់ នោះទេ, យើងខ្ញុំរង់ចាំការបំភ្លឺជានិច្ចពីភាគីសណ្ឋាគារសុខា ជុំវិញបញ្ហាខាងលើនេះ។

សូមជំរាបថា នាពេលថ្មីៗនេះ ប្រជាពលរដ្ឋ មន្ត្រីរាជការ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បាននាំគ្នារិះគន់អាជ្ញាធរដែនដី និងមន្ទីរជំនាញពាក់ព័ន្ធ ដែលបណ្តែតបណ្តោយឲ្យការដ្ឋានសំណង់សណ្ឋាគារលំដាប់ផ្កាយ៥ XI-HU International Hotel Co., Ltd នៅក្បែរឆ្នេរ សណ្ឋាគារ សុខា ក្រុងព្រះសីហនុ ដែលបានចាក់ដីក្រហម រំលោភយកអូរ និងដីចំណីរឆ្នេរសមុទ្រ យ៉ាងអនាធិបតេយ្យ មិនតែប៉ុណ្ណោះ ពេលដែលភ្លៀងធ្លាក់ មកម្តងៗដីក្រហមនោះបានហូរចូលសមុទ្រ បានប្រែក្លាយទឹកសមុទ្រពីពណ៍ខៀវស្រងាត់គួរឲ្យមុជលេង ទៅជាពណ៍ក្រហមគួរឲ្យខ្លាចទៅវិញ ប៉ុន្តែឥឡូវនេះត្រូវបានតំណាងក្រុមហ៊ុនចេញមុខអះអាងថា ទឹកក្រហមដែលហូរចូលទឹកសមុទ្រនោះ គឺហូរចេញពីសណ្ឋាគារសុខា៕


















---

Copyright © 2021 FN Media Co.,Ltd.

Data Center By Fresh News



បើក គណនីថ្មី ឥឡូវនេះ
ទទួលបានប្រូម៉ូកូដតម្លៃ
$12
ពី Wingmall
ដោនឡូត
Wing Bank